**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖១១៥៦ អ.ក
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២
សាលក្រមលេខ៖០៥២ /២៣-ធ-
ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣

# សាលក្រមព្រហ្មទណ្ឌ
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង០៣ និង០០ នាទី រសៀល និងប្រកាសសាលក្រម នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖១១៥៦ អ.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted]ចំណាត់ ហៅ ណាត់ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ខ្នា (រ) ម្ដាយឈ្មោះ [redacted] នី (រ) នៅរស់ ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ១ ឆ្នាំ ៦ ខែ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

២.ឈ្មោះ [redacted]សៀងឡេង ភេទប្រុស អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ធា (រ) ម្ដាយឈ្មោះ [redacted] ប៉ូលីន (រ) នៅរស់ ជាអនីតិជន ទោសពីមុន៖គ្មាន។

៣.ឈ្មោះ [redacted]ភារិទ្ធ ហៅ គ្រីន ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូមិ[redacted] ខេត្តព្រះសីហនុ និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិមនោរម្យ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] អ៊ិន(រ) ម្ដាយឈ្មោះ [redacted] សុខឃឿន (រ) ប្រពន្ធឈ្មោះ [redacted]រតនា (លែងលះ) មានកូនចំនួន០១ នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ១ ឆ្នាំ ៦ ខែ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

៤.ឈ្មោះ [redacted]លីហ្សរ ហៅ ដេវ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]សុគ្រា (រ) ម្ដាយឈ្មោះ [redacted] សុភ័ណ្ឌ (រ) នៅរស់ ជានីតិជន ទោសពីមុន៖គ្មាន។



Scanned with CamScanner

៥.ឈ្មោះ [redacted]វន្នី ហៅ តុង ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]ម៉ាន (ស) ម្តាយឈ្មោះ [redacted]ផូ (រ) នៅលីវ ជាអនីតិជន ទោសពីមុនៈគ្មាន។

៦.ឈ្មោះ [redacted]មករា ហៅ ផាំ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សុខឆាយ(ស) ម្តាយឈ្មោះ [redacted] ជានី (រ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ៦ ខែ ពីបទៈ លួច ។

៧.ឈ្មោះ [redacted]រ៉ាយុទ្ធ ភេទប្រុស អាយុ១៥ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូមិ និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]វណ្ណៈ(រ) ម្តាយឈ្មោះ [redacted]ភា (រ) នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ៦ ខែ ពីបទៈ លួចមានស្ថានទម្ងន់ទោស។

៨.ឈ្មោះ [redacted]សីហា ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូមិ និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]យៀប (រ) ម្តាយឈ្មោះ [redacted] ប្រិប (រ) ពោះម៉ាយ មានកូនចំនួន០១ នាក់ ទោសពីមុនៈគ្មាន។

ត្រូវជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

មានលោកស្រី [redacted] ជាមេធាវីចាត់តាំងការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សៀងឡេង និងឈ្មោះ [redacted]រ៉ាយុទ្ធ មានការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេត្តកណ្តាល។

មានលោក [redacted] ជាមេធាវីចាត់តាំងការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ចំណាត់ ហៅណាត់,ឈ្មោះ [redacted]ការិទ្ធិ ហៅ គ្រិន,ឈ្មោះ [redacted]លីហួរ ហៅ វេវ ,ឈ្មោះ អុក វន្នី ហៅ តុង ,ឈ្មោះ [redacted]មករា ហៅ ផាំ និងឈ្មោះ [redacted]សីហា មានការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេត្តកណ្តាល។

**ដើមបណ្តឹងរដ្ឋប្បវេណីៈ**

-ឈ្មោះ [redacted] ស្រីនួន ភេទស្រី អាយុ៣៣ឆ្នាំ មុខរបរជាងអ៊ុតសក់ មានអាសយដ្ឋាននៅភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។

-ឈ្មោះ [redacted]សុផល ភេទស្រី អាយុ៥២ឆ្នាំ មុខរបរកម្មកររោងចក្រ មានអាសយដ្ឋាននៅភូមិខ្លោការ ឃុំបារុង ស្រុកល្វាឯម ខេត្តកណ្តាល។

-ឈ្មោះ [redacted]លីស្រេន ភេទស្រី អាយុ១៧ឆ្នាំ មានអាសយដ្ឋាននៅភូមិកៅ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ១២៨០ ដកសព/២២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខៈ១៣២២ ដកដស ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខៈ១៤៥០ ដកចត/២២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។



Scanned with CamScanner

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ៖**

កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង៧ និង៤៥នាទីមានករណី លួចមានស្ថានទម្ងន់ទោស តាមបណ្តោយផ្លូវជាតិលេខ៤ ស្ថិតនៅភូមិព្រៃកទម្លាប់ខ្ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល បង្កឡើងដោយឈ្មោះ [redacted] ចំណាត់ ,ឈ្មោះ [redacted] ភារិទ្ធ [redacted] រ៉ាយុទ្ធ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី ,ឈ្មោះ [redacted] មករា ,ឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] បានធ្វើសកម្មភាពឆក់កាបូបពីជនរងគ្រោះឈ្មោះ [redacted] ស្រីនួន ភេទស្រី អាយុ៣០ ឆ្នាំ ខណៈពេលដែលជនរងគ្រោះកំពុងជិះម៉ូតូតាមផ្លូវទៅផ្សារ ក៏ត្រូវបានក្រុមជនសង្ស័យធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ជនរងគ្រោះឈ្មោះ [redacted] លីគ័ន ភេទស្រី អាយុ១៧ ឆ្នាំ។ ក្រោយពេលឆក់ទូរស័ព្ទ និងកាបូបរបស់ជនរងគ្រោះបាន ក្រុមជនសង្ស័យបានយកទូរស័ព្ទ និងរបស់មានតម្លៃទៅលក់ ដើម្បីយកលុយមកចែកគ្នាចាយ។ លុះដល់ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២ ក្រុមជនសង្ស័យបានជិះម៉ូតូមួយគ្រឿងម៉ាកសង់C125 ជិះគ្នាចំនួន០៣ នាក់ ចេញពីផ្ទះក្នុងគោលបំណងទៅឆក់អ្នកដំណើរតាមផ្លូវជាតិលេខ៤ ដូចរាល់ដង។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] សៀងឡេង បានឆ្លើយនៅពេលសវនាការថា៖ កន្លងមកខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] ចំណាត់ ធ្លាប់បានធ្វើសកម្មភាពឆក់បានចំនួន០២ លើក ហើយនៅពេលធ្វើសកម្មភាពឆក់ម្តងៗ ខ្លួនជាអ្នកឌុប ពេលខ្លះខ្លួនជិះពីក្រោយគេវិញ ប៉ុន្តែខ្លួនមិនដែលឆក់គេតាមផ្លូវទេ គ្រាន់តែរួមដំណើរជាមួយ អ្នកដែលឆក់គឺឈ្មោះ [redacted] ចំណាត់ ឆក់បានចំនួន០២ ដង បន្ទាប់ពីឆក់បានទូរស័ព្ទឈ្មោះ [redacted] ចំណាត់ ជាអ្នកយកទូរស័ព្ទទៅលក់ បានប្រាក់ឲ្យមកខ្លួនបន្តិចបន្តួចដែរ ចំណែកអ្នកផ្សេងៗនោះ គឺខ្លួនមិនដែលបានធ្វើសកម្មភាពឆក់ជាមួយទេ គ្រាន់តែធ្លាប់ស្គាល់គ្នា។
- ជនជាប់ចោទឈ្មោះ [redacted] ចំណាត់ បានឆ្លើយនៅពេលសវនាការថា៖ ខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដំណើរតាមផ្លូវបានចំនួន១២ លើកមកហើយ ជាមួយក្រុមរបស់ខ្លួនមានឈ្មោះ ឈ្មោះ [redacted] ភារិទ្ធិ ហៅ គ្រិន,ឈ្មោះ [redacted] លីហួរ ហៅ វេវ ,ឈ្មោះ [redacted] វន្នី ហៅ តុង ,ឈ្មោះ [redacted] មករា ហៅ ឆាំ,ឈ្មោះ [redacted] សៀងឡេង និងឈ្មោះ [redacted] សីហា ភាគច្រើនទូរស័ព្ទដៃដែលពួកខ្លួនឆក់បានគឺអ្នកដំណើរដាក់ហោប៉ៅក្រោយ និងចំហៀង ដោយដាក់លៀនចេញមកក្រៅទើបខ្លួនឆក់តែម្តង។ ពេលឆក់បាន គឺយកទៅលក់បានប្រាក់ចំនួន១២០.០០០ រៀល ទៅ១៤០.០០០ រៀលតែប៉ុណ្ណោះ ក្រោយពីលក់បាន គឺពួកខ្លួនចែកគ្នាចាយអស់ហើយ។
- ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ បានឆ្លើយពេលសវនាការថា៖ ខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដំណើរតាមផ្លូវបានចំនួន០២ លើកមកហើយ ជាមួយឈ្មោះ រ៉ា នៅម្តុំភ្នំពេញទួលគោក នៅពេលធ្វើសកម្មភាពនោះគឺឈ្មោះ រ៉ា ជាអ្នកឌុបខ្លួនជិះពីក្រោយ ពេលឆក់ទូរស័ព្ទបាននោះគឺភាគច្រើនអ្នកដំណើរទុកទូរស័ព្ទនៅខាងក្រោយ។ នៅពេលដែលឆក់បាននោះគឺឈ្មោះ រ៉ា ជាអ្នកយកទៅលក់បានប្រាក់ចំនួន៣០០$ ឲ្យខ្លួនចំនួន២០០$ លើកទី២ យកទៅលក់បានប្រាក់ចំនួន៣២០$ ដោយឈ្មោះ រ៉ា ជាអ្នកយកទៅលក់ដដែល ហើយប្រាក់លក់បាន គឺឈ្មោះ រ៉ា មិនបានឲ្យមកខ្លួនទេ គឺឈ្មោះ រ៉ា យកទៅធ្វើម៉ូតូអស់ទៅ។ ចំណែកឈ្មោះ [redacted] ចំណាត់ ,ឈ្មោះ [redacted] ភារិទ្ធ ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី ,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា គឺខ្លួនមិនដែលស្គាល់ ហើយក៏មិនដែលបានធ្វើសកម្មភាពឆក់ជាមួយដែរ គឺខ្លួនស្គាល់តែឈ្មោះ [redacted] សៀងឡេង ទេ ហើយមិនដែលបានធ្វើសកម្មភាពឆក់ជាមួយគ្នាទេ។



Scanned with CamScanner

- ជនជាប់ចោទឈ្មោះ [redacted] ភារិទ្ធិ ហៅ ក្រិន បានឆ្លើយពេលសវនាការថា៖ ខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដំណើរតាមផ្លូវបានចំនួន០៧ លើកមកហើយ នៅថ្ងៃផ្សេងៗគ្នាជាមួយឈ្មោះ [redacted] ចំណាត់ បាន០៧លើក ក្រៅពីនេះខ្លួនបានធ្វើសកម្មភាពឆក់តែម្នាក់ឯងទេ ចំណែកឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី ,ឈ្មោះ [redacted] មករា ,ឈ្មោះ [redacted] រ៉ាយុទ្ធ ,ឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] សៀងឡេង មិនពាក់ព័ន្ធជាមួយខ្លួននោះទេ។ ក្រោយពីខ្លួនឆក់បាន គឺខ្លួនយកទៅលក់នៅហាងលក់ទូរស័ព្ទដៃមិនចាំឈ្មោះហាងទេ ហើយទូរស័ព្ទដៃដែលលក់បានក្នុងមួយគ្រឿងតម្លៃ១៥០.០០០ រៀល លុយដែលក់បាន គឺយកទៅផ្គត់ផ្គង់គ្រួសារអស់ហើយ។
- ជនជាប់ចោទឈ្មោះ [redacted] សីហា បានឆ្លើយពេលសវនាការថា៖ ខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដំណើរតាមផ្លូវបានចំនួន០២ លើកមកហើយ នៅផ្លូវជាតិលេខ៤ ជាមួយឈ្មោះ [redacted] ចំណាត់ ដោយខ្លួនជាអ្នកបើកម៉ូតូ រីឯឈ្មោះ [redacted] ចំណាត់ ជាអ្នកជិះពីក្រោយឆក់ក្នុងរាជធានីភ្នំពេញ ក្នុងមួយថ្ងៃពួកខ្លួនចេញឆក់២ដង។ ក្រោយពីឆក់បានឈ្មោះ [redacted] ចំណាត់ ជាអ្នកយកទៅលក់ ខ្លួនមិនដឹងថាបានប្រាក់ចំនួនប៉ុន្មានទេ ហើយឈ្មោះ [redacted] ចំណាត់ ក៏មិនបានឲ្យលុយមកខ្លួនដែរ ពីព្រោះខ្លួនបានចេញដំណើរទៅខេត្តកោះកុងមកធ្វើការជាមួយក្រុមហ៊ុនឯកជន។ លុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ សមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនតែម្តង។ ចំណែកឈ្មោះ [redacted] ចំណាត់ ,ឈ្មោះ [redacted] ភារិទ្ធ ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី ,ឈ្មោះ [redacted] មករា ,ឈ្មោះ [redacted] សៀងឡេង និងឈ្មោះ [redacted] រ៉ាយុទ្ធ គឺខ្លួនស្គាល់ពួកវាដែរ សុទ្ធតែអ្នកភូមិរស់នៅជាមួយគ្នា តែខ្លួនមិនដែលបានធ្វើសកម្មភាពឆក់ជាមួយពួកវាទេ។
- ជនជាប់ចោទឈ្មោះ [redacted] លីហួរ ហៅ វ៉េវ បានឆ្លើយពេលសវនាការថា៖ ខ្លួនមិនដែលធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដំណើរតាមផ្លូវទេ។ ទើបមកដល់ថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ចំណាត់ ពីក្រោយ ដោយឈ្មោះ [redacted] ចំណាត់ ជាអ្នកឌុបខ្លួន ហើយគាត់បានធ្វើសកម្មភាពឆក់ទូរស័ព្ទពីអ្នកដំណើរតាមផ្លូវ ដោយខ្លួនមិនបានដឹងខ្លួនទេ។ ក្រោយពីឆក់ទូរស័ព្ទបានគាត់បានជូនខ្លួនដាក់នៅផ្ទះខ្លួនវិញ លុះមួយសន្ទុះក្រោយមកឈ្មោះ [redacted] ចំណាត់ បានជិះម៉ូតូមកផ្ទះខ្លួន រួចហុចលុយឲ្យ១០$ តែខ្លួនមិនបានទទួលពីគាត់ទេ ដោយខ្លាចជាប់ពាក់ព័ន្ធនៅក្នុងរឿងឆក់នោះ។ ចំណែកឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] ភារិទ្ធ ,ឈ្មោះ [redacted] វន្នី ,ឈ្មោះ [redacted] មករា ,ឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] រ៉ាយុទ្ធ សុទ្ធតែធ្លាប់ស្គាល់ តែខ្លួនមិនដែលប្រព្រឹត្តជាមួយពួកគាត់ទេ។
- ជនជាប់ចោទឈ្មោះ [redacted] វន្នី បានឆ្លើយពេលសវនាការថា៖ ខ្លួនជាអ្នកជិះពីក្រោយ ឈ្មោះ សម្បត្តិ ជាអ្នកឌុបខ្លួន ពេលឆក់បានគឺទូរស័ព្ទOPPO រួចយកទៅលក់បានប្រាក់យកទៅចែកគ្នាស្មើ។ នៅពេលដែលធ្វើសកម្មភាព ខ្លួនចេះជក់ថ្នាំញៀនរយៈពេល៣ ឆ្នាំមកហើយ ដោយជក់ក្នុង១ ខែ ២០ដង។
- ជនជាប់ចោទឈ្មោះ [redacted] មករា បានឆ្លើយពេលសវនាការថា៖ នៅថ្ងៃកើតហេតុខ្លួនបានធ្វើសកម្មឆក់បានទូរស័ព្ទម៉ាកOPPO ហើយយកទៅលក់បានប្រាក់២៨០$ ខ្លួនមានមុខរបរធ្វើការសងពេងការតាមកម្មវិធីការ។ កន្លងមកខ្លួនបានធ្វើសកម្មភាពឆក់បាន២លើកមកហើយជាមួយឈ្មោះ ចំណាត់ ហៅ ណាត់ ខ្លួនដឹងថាអំពើឆក់នេះជាអំពើខុសច្បាប់ ខ្លួនស្គាល់ឈ្មោះ ចំណាត់ នេះតាមរយៈការផឹកស៊ីជុំជាមួយគ្នា។
- តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីស្រ៊ន បានឆ្លើយថា កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង៤ និង៣០ នាទី ពេលនាងខ្ញុំកំពុងជិះម៉ូតូមកធ្វើការពេងចក្រនៅ



ក្រឡាបញ្ជី [redacted]

Scanned with CamScanner

ឃុំព្រៃពួច នៅចំណុចមុខរោងចក្រ ក៏ស្រាប់តែមានជនមិនស្គាល់មុខ បានមកឆក់យកទូរស័ព្ទម៉ាក អាហ្វូនស៊ិច ពណ៌ខ្មៅ (តម្លៃ១៩២$) បក្សពួកក្រុមចោរឆក់នោះមានពីរម៉ូតូ គ្នា៤នាក់។

- តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនួន បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង៧ និង៤៥ នាទី នាងខ្ញុំបានធ្វើដំណើរចេញពីផ្ទះតាមផ្លូវជាតិលេខ៤ គោលបំណងទៅផ្សារថ្នល់ទទឹង ដើម្បីបើកតូបអ៊ុតសក់ដូចសព្វដង។ លុះមកដល់ចំណុចកើតហេតុមានជនមិនស្គាល់ឈ្មោះ មានគ្នាចំនួន០២ នាក់ជិះម៉ូតូមួយគ្រឿងម៉ាកសង់ពណ៌ខ្មៅមិនស្គាល់ស្លាកលេខ បានឆក់កាបូបពីចង្កេះនាងខ្ញុំ រួចជនទាំងនោះក៏បានជិះម៉ូតូគេចខ្លួនទៅខាងលិចបាត់។ សំភារៈដែលនាងខ្ញុំបាត់បង់មានទូរស័ព្ទម៉ាកអាយហ្វូនមួយគ្រឿង អត្តសញ្ញាណមួយសន្លឹក កាតចាក់វ៉ាក់សាំងមួយសន្លឹក និងប្រាក់ចំនួន៧០០.០០០ រៀល។
- តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល បានឆ្លើយថា កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង៤ ជាង កូនស្រីនាងខ្ញុំបានមកដល់ផ្ទះមានសភាពភ័យយ៉ាងខ្លាំង បន្ទាប់ពីកើតហេតុរួច ដោយបានប្រាប់ថា មានចោរឆក់ទូរស័ព្ទដៃរបស់វា ដែលបានដាក់ក្នុងឃ្លុបម៉ូតូខាងមុខ។ នៅក្នុងរឿងនេះ នាងខ្ញុំមិនទាមទារសំណងពីជនបង្កទេ ទុកឲ្យតុលាការជាអ្នកសម្រេចតាមច្បាប់។
- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖ តាមរយៈការពិភាក្សាសួរដេញដោលនៅក្នុងសវនាការ ជនជាប់ចោទឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] រ៉ាយុទ្ធ ,ឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា បានសារភាពថា ពិតជាបានធ្វើសកម្មភាពឆក់ទូរសព្ទរបស់ជនរងគ្រោះតាមផ្លូវ កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ប្រព្រឹត្តនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ពិតប្រាកដមែន។ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] រ៉ាយុទ្ធ ,ឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា ពិតជាមានពិរុទ្ធភាពក្នុងអំពើ លួចមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២។ ដូច្នេះតំណាងអយ្យការ សូមតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ:១២៨០ ដកសព/២២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ទុកជាបានការដដែល និងសូមឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ តាមច្បាប់។
- សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សៀងឡេង និងឈ្មោះ [redacted] រ៉ាយុទ្ធ ធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖ តាមរយៈការពិភាក្សាសួរដេញដោលនៅក្នុងសវនាការកូនក្តីខ្លួនទាំងពីរនាក់ បានសារភាព និងទទួលស្គាល់កំហុសអំពីការចោទប្រកាន់របស់តុលាការ ពីបទ៖ លួចមានស្ថានទម្ងន់ទោស។ ការណ៍ដែលកូនក្តីខ្លួនប្រព្រឹត្តសកម្មភាពនេះ ដោយសារភាពល្ងិតល្ងង់ ហើយរឹតម្យ៉ាងទៀតកូនក្តីខ្លួនឈ្មោះ [redacted] សៀងឡេង ជាអនីតិជន។ ដូច្នេះខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសតាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ។
- សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា ធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖ តាមរយៈការពិភាក្សាសួរដេញដោលនៅក្នុងសវនាការកូនក្តីខ្លួនទាំងអស់ បានសារភាព និងទទួលស្គាល់កំហុសអំពីការចោទប្រកាន់របស់តុលាការ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ។ ដូច្នេះ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជន



Scanned with CamScanner

ជាប់ចោទទាំងអស់ ស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោស និងសម្រេចផ្តល់នូវស្ថានសម្រាលទោសដល់ជនជាប់ចោទ តាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើភស្តុតាង
- ក្រោយពីបានស្តាប់សំណូមពរដែលជាសំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. ផ្អែកតាមកំណត់ហេតុរបស់នគរបាលយុត្តិធម៌ , ឯកសារភស្តុតាងដែលមានក្នុងសំណុំរឿង ធៀបជាមួយនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] វ៉ាយុទ្ធ,ឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហ្សូរ ,ឈ្មោះ [redacted] វន្នី,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា នៅគ្រប់ដំណាក់កាលទាំងអស់បង្ហាញឃើញថា អង្គហេតុទាំងឡាយដែលតំណាងអយ្យការបានបើកការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] វ៉ាយុទ្ធ,ឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហ្សូរ ,ឈ្មោះ [redacted] វន្នី,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា ដែលបានបញ្ជូនឱ្យចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះ គឺអាចកំណត់ពីអត្ថិភាពនៃអង្គហេតុពិត ដែលតុលាការជំនុំជម្រះត្រូវវាយតម្លៃអំពី ពិរុទ្ធភាពរបស់ជនជាប់ចោទដោយផ្អែកលើភស្តុតាង។

២. ចំពោះជនជាប់ចោទឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ភេទប្រុស អាយុ២១ឆ្នាំ ,ឈ្មោះ [redacted] សៀងឡេង ភេទប្រុស អាយុ១៦ឆ្នាំ ,ឈ្មោះ [redacted] ភារិទ្ធ ហៅគ្រិន ភេទប្រុស អាយុ២១ឆ្នាំ ,ឈ្មោះ [redacted] លីហ្សូរ ហៅ វេវ ភេទប្រុស អាយុ១៨ឆ្នាំ ,ឈ្មោះ [redacted] វន្នី ហៅ តុង ភេទប្រុស អាយុ២៦ឆ្នាំ ,ឈ្មោះ [redacted] មករា ហៅ ផាំ ភេទប្រុស អាយុ១៨ឆ្នាំ ,ឈ្មោះ [redacted] វ៉ាយុទ្ធ ភេទប្រុស អាយុ១៥ ឆ្នាំ ,ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ២៥ឆ្នាំ ត្រូវបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល តុលាការពិនិត្យឃើញថា ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] វ៉ាយុទ្ធ,ឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហ្សូរ ,ឈ្មោះ [redacted] វន្នី,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា នៅពេលសវនាការបានឆ្លើយសារភាពប្រហាក់ប្រហែលគ្នាថា "ពួកខ្លួនពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ជនរងគ្រោះតាមដងផ្លូវពិតប្រាកដមែន ដោយពួកខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដំណើរតាមផ្លូវជាច្រើន ដែលក្រុមរបស់ពួកខ្លួនមានឈ្មោះ [redacted] ភារិទ្ធិ ហៅ គ្រិន,ឈ្មោះ [redacted] លីហ្សូរ ហៅ វេវ ,ឈ្មោះ [redacted] វន្នី ហៅ តុង ,ឈ្មោះ [redacted] មករា ហៅ ផាំ,ឈ្មោះ [redacted] សៀងឡេង និងឈ្មោះ [redacted] សីហា ហើយទូរស័ព្ទដៃដែលពួកខ្លួនឆក់បាន គឺអ្នកដំណើរដាក់ហោប៉ៅក្រោយ និងចំហៀងដោយដាក់លៀនចេញមកក្រៅទើបខ្លួនឆក់តែម្តង។ ពេលឆក់បាន គឺយកទៅលក់បានប្រាក់ គឺពួកខ្លួនចែកគ្នាចាយ" ដែលចម្លើយនេះបើធៀបជាមួយភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងអាចវាយតម្លៃបានថា អំពើរបស់ជនជាប់ចោទទាំងនេះ គឺជាសកម្មភាពនៃការប្រើកម្លាំង ដើម្បីទាញយក ឬកញ្ឆក់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយជនជាប់ចោទទាំងនេះប្រើប្រាស់ម៉ូតូជាមធ្យោបាយប្រព្រឹត្តបទល្មើស ដែលឃើញថា អំពើត្រង់ចំណុចនេះបានបំពេញជាគុសត្យានុម័តនៃបទៈ លួចមានស្ថានទម្ងន់

ទោស ហើយជនជាប់ចោទឈ្មោះ [redacted] ចំណាត់,ឈ្មោះ [redacted] ភារិទ្ធ,ឈ្មោះ [redacted] លីហួរ ,ឈ្មោះ [redacted] វន្នី ,ឈ្មោះ [redacted] មករា និងឈ្មោះ [redacted] សីហា មិនមែនជាអនីតិជន ឬជនវិប្បឡាសស្មារតីនោះទេ ហេតុនេះអំពើរបស់ជនទាំងនេះក៏បានបំពេញជាគុអត្តនោម័តនៃបទល្មើសខាងលើផងដែរ រីឯជនជាប់ចោទឈ្មោះ [redacted] សៀងឡេង និងឈ្មោះ [redacted] រ៉ាយុទ្ធ ថ្វីត្បិតជាអនីតិជន ប៉ុន្តែមានអាយុធួនល្មម ដែលអាចយល់ដឹងពីលទ្ធផលនៃសកម្មភាពរបស់ខ្លួនតាមផ្លូវច្បាប់ហើយ ហើយដោយផ្អែកតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ដែលជាធាតុនីត្យានុកូលឃើញថា អំពើខាងលើបានបំពេញជាធាតុផ្សំគ្រប់គ្រាន់នៃបទ៖ លួចមានស្ថានទម្ងន់ទោស ពិតប្រាកដមែន។

៣. យល់ឃើញថា តាមអំណានចម្លើយរបស់ជនរងគ្រោះ [redacted] លីស្រ៊ន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនួន បានឆ្លើយថា " កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ពិតជាមានករណីចោរឆក់ទូរស័ព្ទ និងកាបូបលុយ ដែលប្រព្រឹត្តឡើងដោយជនត្រូវចោទឈ្មោះ [redacted] ចំណាត់ ហៅណាត់ ,ឈ្មោះ [redacted] សៀងឡេង និងបក្សពួក នៅចំណុចផ្លូវជាតិលេខ៤ ស្ថិតនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ពិតប្រាកដមែន "។

៤. យល់ឃើញថា តំណាងអយ្យការបានធ្វើការសន្និដ្ឋានលើសំណុំរឿងព្រហ្មទណ្ឌលេខ៖១១៥៦ អ.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ ថាពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ភេទប្រុស អាយុ២១ឆ្នាំ ,ឈ្មោះ [redacted] សៀងឡេង ភេទប្រុស អាយុ១៦ឆ្នាំ ,ឈ្មោះ [redacted] ភារិទ្ធ ហៅគ្រិន ភេទប្រុស អាយុ២១ឆ្នាំ ,ឈ្មោះ [redacted] លីហួរ ហៅ វេរ ភេទប្រុស អាយុ១៨ឆ្នាំ , ឈ្មោះ [redacted] វន្នី ហៅ តុង ភេទប្រុស អាយុ២៦ឆ្នាំ ,ឈ្មោះ [redacted] មករា ហៅ ធាំ ភេទប្រុស អាយុ១៨ឆ្នាំ , ឈ្មោះ [redacted] រ៉ាយុទ្ធ ភេទប្រុស អាយុ១៥ ឆ្នាំ ,ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ២៥ឆ្នាំ ,ឈ្មោះ សម្បត្តិ ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ហេតុនេះតំណាងអយ្យការប្តឹងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ៖១២៨០ ដកស៧/២២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ទុកជាបានការពេញលេញទាំងមូល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៥. យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទខាងលើបានស្នើសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនបានឆ្លើយសារភាពពីទង្វើរបស់ខ្លួន និងបានទទួលស្គាល់ការចោទប្រកាន់របស់តុលាការ នូវអំពើលួចមានស្ថានទម្ងន់ទោស ដោយសារតែកូនក្តីខ្លួន មានការយល់ដឹងតិច មិនបានសិក្សារៀនសូត្រច្រើន នេះបង្ហាញឱ្យឃើញពីស្មារតីសហការណ៍ផ្តល់ការពិតដល់សវនាការ ហេតុនេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាទៅលើកម្រិតនៃការផ្តន្ទាទោសលើកូនក្តីរបស់ខ្លួន គប្បីតុលាការធ្វើការពិចារណា។

៦. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សៀងឡេង ,ឈ្មោះ [redacted] រ៉ាយុទ្ធ,ឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ,ឈ្មោះ [redacted] ភារិទ្ធ ហៅគ្រិន ,ឈ្មោះ [redacted] លីហួរ ហៅវេរ ,ឈ្មោះ [redacted] វន្នី ហៅតុង ,ឈ្មោះ [redacted] មករា ហៅធាំ និងឈ្មោះ [redacted] សីហា បានឆ្លើយសារភាពពីទង្វើរបស់ខ្លួន ដែលបង្ហាញឱ្យឃើញពីស្មារតីសហការណ៍ផ្តល់ការពិតដល់សវនាការ ហេតុនេះគប្បីតុលាការពិចារណាទៅលើកម្រិតនៃការផ្តន្ទាទោសលើជនជាប់ចោទ។

៧.យល់ឃើញថា៖ ដើមបណ្តឹងរដ្ឋប្បវេណីមិនបង្ហាញខ្លួននៅពេលសវនាការ ហេតុនេះតុលាការមិនអាចស្តាប់ការអះអាងចំពោះការទាមទារ ឬមិនទាមទារសំណងផ្នែករដ្ឋប្បវេណីនោះទេ ហើយនៅដំណាក់កាលមុនៗ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងការខូចខាតឡើយ។



Scanned with CamScanner

## ហេតុដូច្នេះ សម្រេចសេចក្តី

-ផ្តន្ទាទោសលើជនជាប់ចោទ

១.ឈ្មោះ [redacted] សៀងឡេង ភេទប្រុស អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ

២.ឈ្មោះ [redacted] វ៉ាយុទ្ធ ភេទប្រុស អាយុ១៥ ឆ្នាំ សញ្ជាតិខ្មែរ

ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល០៣ (បី) ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ

៤.ឈ្មោះ [redacted] ភារិទ្ធ ហៅ គ្រិន ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ

៥.ឈ្មោះ [redacted] លីហួរ ហៅ វេវ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ

៦.ឈ្មោះ [redacted] វន្ធី ហៅ តុង ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ

៧.ឈ្មោះ [redacted] មករា ហៅ ផាំ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ

៨.ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ

ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល០៥ (ប្រាំ) ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំណាត់ ហៅ ណាត់ ,ឈ្មោះ [redacted] សៀងឡេង, ឈ្មោះ [redacted] ភារិទ្ធ ហៅគ្រិន, ឈ្មោះ [redacted] លីហួរ ហៅ វេវ ,ឈ្មោះ [redacted] វន្ធី ហៅ តុង ,ឈ្មោះ [redacted] មករា ហៅ ផាំ ,ឈ្មោះ [redacted] វ៉ាយុទ្ធ ,ឈ្មោះ [redacted] សីហា និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនួន ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] លីស្រ៊ន។

*ទុកសិទ្ធិប្តឹងទាស់ ឬឧទ្ធរណ៍ក្នុងកំណត់ច្បាប់។*

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៤រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

ក្រឡាបញ្ជី [redacted]



Scanned with CamScanner